ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**
សំណុំរឿងរដ្ឋប្បវេណីលេខ ៦៦៦
ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២
សាលក្រមលេខ: **០១៥(ឆ)**
ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**
សាលាដំបូងខេត្តកណ្ដាល
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២៣
ដោយមានសមាសភាព:
-លោក [redacted] ចៅក្រម
-លោក [redacted] ក្រឡាបញ្ជី

**-សហដើមចោទ៖**

.ឈ្មោះ: [redacted] **សុធា** ភេទ ប្រុស កើតនៅថ្ងៃទី ០៨.០២.១៩៥៣ និងប្រពន្ធ ឈ្មោះ: [redacted] **ស៊ីវអេង** ភេទស្រី កើតនៅថ្ងៃទី ១៨.០៥.១៩៧៥ មានអាសយដ្ឋាននៅភូមិក្នុង [redacted] ។

មានអ្នកតំណាងដោយអាណត្តិ**លោក** [redacted] អត្តលេខ ២០៨០ និង**លោក** [redacted] អត្តលេខ:២៨១១ ជាមេធាវី ។

**-សហចុងចម្លើយ៖**

.ឈ្មោះ: [redacted] **ស្រេន** ភេទប្រុស កើតថ្ងៃទី០៥.០៤.១៩៦៩ និងប្រពន្ធឈ្មោះ: [redacted] **សាត** កើតនៅថ្ងៃទី ០៣.០៤.១៩៧១ មានអាសយដ្ឋានសព្វថ្ងៃនៅភូមិ [redacted] ។

.ឈ្មោះ: [redacted] **ម៉ូរ៉ា** ភេទប្រុស កើតថ្ងៃទី០៤.១០.១៩៨៦ មានអាសយដ្ឋានសព្វថ្ងៃនៅ [redacted] ។

មានអ្នកតំណាងដោយអាណត្តិឈ្មោះ: [redacted] អត្តលេខ ៨៣៨ ,ឈ្មោះ: [redacted] អត្តលេខ ២៧០០T ជាមេធាវី និងឈ្មោះ: [redacted] អត្តលេខ ២៧០៤T ជាមេធាវី ,ឈ្មោះ: [redacted] អត្តលេខ ២៦៩៩ T ។

**អង្គហេតុ និងចំណុចវិវាទ៖**

**<u>១.១.ខ្លឹមសារសាលក្រមដែលទាមទារដោយដើមចោទ:</u>**

ក.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ: [redacted] ស្រេន និងប្រពន្ធឈ្មោះ: [redacted] សាត បង់ប្រាក់ប្រាក់ដើមចំនួន ១០១.៥៥០$(ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) និងបង់ការប្រាក់



Scanned with CamScanner

ក្នុងអត្រា ១.៥% ក្នុងមួយខែ នៃប្រាក់ដើមចំនួន ១០១.៥៥០$(ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី១១.០៥.២០១៧ រហូតដល់ថ្ងៃសងរួច ឲ្យទៅដើមចោទឈ្មោះ [redacted]សុធា និងប្រពន្ធឈ្មោះ[redacted] ស៊ីវអេង ។

ខ.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] បូរ៉ា និងឈ្មោះ [redacted] ស្រេន បង់ប្រាក់ដើមចំនួន ៦០០០$ (ប្រាំមួយពាន់0ដុល្លាអាមេរិក) និងបង់ការប្រាក់ក្នុងអត្រា ១.៥% ក្នុងមួយខែ នៃប្រាក់ដើមចំនួន ៦០០០$(ប្រាំមួយពាន់)ដុល្លារអាមេរិក គិតពីថ្ងៃទី ១៦.១១.២០១៧ រហូតដល់ពេលសងរួចឲ្យមកដើមចោទឈ្មោះ[redacted] សុធា និងប្រពន្ធឈ្មោះ [redacted] ស៊ីវអេង។

គ.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ[redacted] ស្រេន ,ឈ្មោះ [redacted] សាត និងឈ្មោះ [redacted] បូរ៉ា រួមគ្នាសងសំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងការចំណាយសេវាកម្មច្បាប់ជាប្រាក់ចំនួន ៣០.០០០$(បីម៉ឺន)ដុល្លារអាមេរិក ឲ្យទៅដើមចោទឈ្មោះ[redacted] សុធា និងប្រពន្ធឈ្មោះ [redacted]ស៊ីវអេង។

ឃ.ប្រាក់ពន្ធនិងប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

ង.កំណត់យកសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន។

**១.២.ខ្លឹមសារសាលក្រមដែលទាមទារដោយដើមបណ្ដឹងតប៖**

ក.ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ[redacted] សុធា និងឈ្មោះ [redacted] ស៊ីវអេង ដែលមានមេធាវី ឈ្មោះ [redacted]និងមេធាវីឈ្មោះ [redacted]ជាអ្នកតំណាង។

ខ.មោឃភាពកិច្ចសន្យាស្ដីពីការខ្ចីប្រាក់ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ រវាងសហចុងបណ្ដឹងតបឈ្មោះ [redacted] សុធា និងឈ្មោះ [redacted] ស៊ីវអេង និងភាគីដើមបណ្ដឹងតបឈ្មោះ [redacted] ស្រេន ,ឈ្មោះ [redacted] សាត ។

គ.មោឃភាពកិច្ចសន្យា ស្ដីពីការខ្ចីប្រាក់ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ រវាសហចុងបណ្ដឹងតបឈ្មោះ [redacted]សុធា និងឈ្មោះ [redacted] ស៊ីវអេង និងភាគីសហដើមបណ្ដឹងតបឈ្មោះ [redacted] ស្រេន និងឈ្មោះ [redacted] បូរ៉ា ។

ឃ.ទាមទារប្រាក់ថ្លៃខូចខាត,ជំងឺចិត្ត និងប្រាក់ថ្លៃសេវាកម្មច្បាប់សរុបចំនួន ២០ ០០០$ (ពីរម៉ឺនដុល្លារអាមេរិក)។

ង.ប្រាក់ពន្ធប្រដាប់ក្ដី និងប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ ជាបន្ទុករបស់ចុងបណ្ដឹងតប។

**២.ការពន្យល់ត្រួសៗអំពីរឿងក្ដី៖**

កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧ សហចុងចម្លើយឈ្មោះ[redacted] ស្រេន និងប្រពន្ធឈ្មោះ [redacted]សាត បានខ្ចីប្រាក់ពីឈ្មោះ [redacted] សុធា និងប្រពន្ធឈ្មោះ [redacted] ស៊ីវអេង ចំនួន ១០១ ៥៥០ $(ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) ដោយមានកិច្ចសន្យា ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧ និងព្រមព្រៀងក្នុងអត្រាការប្រាក់ចំនួន ១,៥% ក្នុងមួយខែ ដោយមានរយៈពេល ៦ខែ គឺចាប់ពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៧ ត្រូវសងប្រាក់មកម្ចាស់ប្រាក់វិញគ្រប់ចំនួនទាំងប្រាក់ដើម និងទាំងការប្រាក់ តែសហចុងចម្លើយពុំបានអនុវត្តបង់ការប្រាក់នោះទេ។ និងនៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ឈ្មោះ [redacted]ស្រេន,ឈ្មោះ [redacted] សាត និងឈ្មោះ [redacted] បូរ៉ា បានរួមគ្នាខ្ចីប្រាក់ពីឈ្មោះ [redacted] សុធា និងប្រពន្ធឈ្មោះ [redacted]



បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានី ថ្ងៃទី 05 ខែ ... ឆ្នាំ 2024
ក្រឡាបញ្ជី
[redacted]

ស៊ីវអេង ចំនួន ៦០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក)បន្ថែមទៀត និងសន្យាឲ្យការប្រាក់ចំនួន ១,៥% ក្នុង១ ខែ គឺរយៈពេលចំនួន ០៦ខែ គឺចាប់ពីថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ដល់ថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៨ ត្រូវសងប្រាក់មកម្ចាស់ប្រាក់វិញគ្រប់ចំនួនទាំងប្រាក់ដើម និងការប្រាក់ចាប់តាំងពីពេលខ្ចីនោះមក សហចុងចម្លើយពុំព្រមសងប្រាក់មកដើមចោទទេ។

**៣-ការអះអាងរបស់ភាគី៖**

.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយសហដើមចោទបានថ្លែងការណ៍ថា៖ ខ្លួននៅតែប្ដឹងសុំឲ្យតុលាការចេញសាលក្រមតាមការទាមទារក្នុងពាក្យបណ្ដឹងចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២២ ដោយសំអាងថា កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧ សហចុងចម្លើយឈ្មោះ[redacted]ស្រេន និងប្រពន្ធឈ្មោះ [redacted] សាត បានខ្ចីប្រាក់ពីឈ្មោះ [redacted]សុធា និងប្រពន្ធឈ្មោះ [redacted] ស៊ីវអេង ចំនួន ១០១.៥៥០$ (ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) ដោយមានកិច្ចសន្យា ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧ និងព្រមព្រៀងក្នុងអត្រាការប្រាក់ចំនួន ១,៥% ក្នុងមួយខែ ដោយមានរយៈពេល ៦ខែ គឺចាប់ពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៧ ត្រូវសងប្រាក់មកម្ចាស់ប្រាក់វិញគ្រប់ចំនួនទាំងប្រាក់ដើម និងទាំងការប្រាក់ តែសហចុងចម្លើយពុំបានអនុវត្តបង់ការប្រាក់នោះទេ និងនៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ឈ្មោះ [redacted] ស្រេន,ឈ្មោះ [redacted]សាត និងឈ្មោះ [redacted] បូរ៉ា បានរួមគ្នាខ្ចីប្រាក់ពីឈ្មោះ [redacted] សុធា និងប្រពន្ធឈ្មោះ [redacted]ស៊ីវអេង ចំនួន ៦០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក)បន្ថែមទៀត និងសន្យាឲ្យការប្រាក់ចំនួន ១,៥% ក្នុង១ ខែ គឺរយៈពេលចំនួន ០៦ខែ គឺចាប់ពីថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ដល់ថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៨ ត្រូវសងប្រាក់មកម្ចាស់ប្រាក់វិញគ្រប់ចំនួនទាំងប្រាក់ដើម និងការប្រាក់ចាប់តាំងពីពេលខ្ចីនោះមក សហចុងចម្លើយពុំព្រមសងប្រាក់មកដើមចោទទេ ទើបសហដើមចោទប្ដឹងមកសាលាដំបូងតែម្ដង។

.លោក [redacted]បានធ្វើសេចក្ដីថ្លែងការណ៍ថា កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ស្រេន,ឈ្មោះ [redacted] សាត និងឈ្មោះ[redacted] បូរ៉ា ជាអ្នកស្គាល់គ្នាជាមួយដើមចោទ និងនៅក្នុងតម្លៃគុណធម៌ កូនក្ដីរបស់ខ្លួន បានបញ្ជាក់ថា ពួកគាត់ពិតជាធ្លាប់បានខ្ចីប្រាក់ពីភាគីដើមចោទពិតមែន។ ក្នុងនាមជាអ្នកតំណាងឲ្យសហចុងចម្លើយ ខ្លួនសូម៖

.ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] សុធា និងឈ្មោះ [redacted] ស៊ីវអេង ដែលមានមេធាវី ឈ្មោះ [redacted] និងមេធាវីឈ្មោះ [redacted]ជាអ្នកតំណាង។

.មោឃភាពកិច្ចសន្យាស្ដីពីការខ្ចីប្រាក់ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ រវាងសហចុងបណ្ដឹងតបឈ្មោះ[redacted]សុធា និងឈ្មោះ [redacted]ស៊ីវអេង និងភាគីដើមបណ្ដឹងតបឈ្មោះ [redacted]ស្រេន ,ឈ្មោះ[redacted]សាត ។

.មោឃភាពកិច្ចសន្យា ស្ដីពីការខ្ចីប្រាក់ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ រវាសហចុងបណ្ដឹងតបឈ្មោះ[redacted]សុធា និងឈ្មោះ [redacted] ស៊ីវអេង និងភាគីសហដើមបណ្ដឹងតបឈ្មោះ [redacted] ស្រេន និងឈ្មោះ [redacted] បូរ៉ា ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
កណ្ដាល, ថ្ងៃទី 05 ខែ ... ឆ្នាំ 2024
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner

.ទាមទារប្រាក់ថ្លៃខូចខាត,ជំងឺចិត្ត និងប្រាក់ថ្លៃសេវាកម្មច្បាប់សរុបចំនួន ២០ ០០០$(ពីរម៉ឺនដុល្លារអាមេរិក)។

.ប្រាក់ពន្ធប្រដាប់ក្តី និងប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ ជាបន្ទុករបស់ចុងបណ្តឹងតប។

ចំពោះមូលហេតុនៃការស្នើសុំច្រានចោល ការទាមទាររបស់ដើមចោទ និងមូលហេតុនៃការស្នើសុំមោឃភាពកិច្ចសន្យាខាងលើមានដូចខាងក្រោមថា៖

កូនក្តីខ្លួនគឺជាអ្នករកស៊ីចងការប្រាក់នៅក្នុងភូមិជន្លឹង ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ប្រភពទុនដែលបានទទួលដើម្បីធ្វើការចងការប្រាក់ទៅឱ្យប្រជាជនក្នុងភូមិគឺបានមកពីការខ្ចីចងការប្រាក់ពីឈ្មោះ [redacted] សុធា និងឈ្មោះ [redacted] ស៊ីវអេង ជាច្រើនឆ្នាំមកហើយ ដើម្បីយកទៅចងការប្រាក់បន្តជាមួយនឹងប្រជាជនក្នុងភូមិ ដោយចំណេញការប្រាក់បន្តិចបន្តួច ។ ការប្រាក់ដែលកូនក្តីខ្លួនយកទៅចងការប្រាក់បន្តនោះគឺ ៣%ក្នុងមួយខែ។ ចំពោះការខ្ចីចងការប្រាក់រវាងកូនក្តីខ្ញុំបាទជាមួយឈ្មោះ [redacted] សុធា និងឈ្មោះ [redacted] ស៊ីវហេង គឺធ្វើឡើងម្តងបន្តិចៗ ដោយមានការធ្វើកិច្ចសន្យាជាច្រើន មិនមែនខ្ចីប្រាក់ម្តងសរុបចំនួន $១០១,៥៥០ ដុល្លារអេមេរិក នោះឡើយ ។ កូនក្តីខ្ញុំបានធ្វើការខ្ចីប្រាក់ជាដំបូងពី ភាគីដើមបណ្តឹងនៅក្នុងឆ្នាំ ២០១៥ និងបន្តរហូតមកដល់ចុងឆ្នាំ ២០១៦ ។

កិច្ចសន្យាដែលចុះនាពេលនោះគឺមានចំនួនច្រើន ដោយធ្វើការខ្ចីប្រាក់ជាច្រើនដំណាក់កាល និងបានធ្វើការចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ទៅតាមពេលនៃការខ្ចីនីមួយៗ ដោយណត់ភាគច្រើនថេរវេលាចំនួន ៦ ខែ ។ កិច្ចសន្យាខ្ចីបចងការប្រាក់ដែលគូភាគីបានចុះជាមួយគ្នាមានចំនួន ២៩ ច្បាប់ ដែលមានដូចជា៖

1. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦
2. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦
3. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦
4. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦
5. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦
6. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦
7. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦
8. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៦
9. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦
10. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៦
11. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦
12. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥
13. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥
14. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥
15. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
កណ្តាល ថ្ងៃទី 05 ខែ ... ឆ្នាំ 2024
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner

ភាគច្រើនគ្រង់ចំណុចដែលនិយាយអំពីចំនួនទឹកប្រាក់កម្ចី, ចំណុចអំពីទ្រព្យធានា និងចំណុចអំពីចំនួនការប្រាក់នោះគឺមិនដែលសរសេរនោះទេ ។

កូនក្ដីរបស់ខ្លួនធ្លាប់ស្នាក់នៅជាមួយនឹងម្ចាស់បំណុលផងដែរនោះ ហេតុដូច្នេះហើយគាត់មិនអាចសួរនាំ ឬសុំអានឯកសារអ្វីបានទាំងអស់ ដោយភាគីម្ចាស់លុយនិយាយសំឡុត គំហកដាក់កូនក្ដីខ្លួន"ឱ្យផ្ដិតឱ្យលឿនៗ"។ ឯកសារដែលកូនក្ដីខ្លួនបានផ្ដិតនៅពេលនោះគឺមានចំនួនច្រើនសន្លឹក ដាក់គរលើគ្នាហើយខាងម្ចាស់លុយបើកឱ្យផ្ដិតតែនៅខាងចុងទំព័រខាងក្រោមតែប៉ុណ្ណោះ ហើយក៏ពុំបានពិនិត្យមើលកិច្ចសន្យាឱ្យអស់ជ្រុងជ្រោយដែរ ។ ក្រោយពីបានផ្ដិតហើយក៏ពុំបានទទួលប្រាក់ពីដើមចោទឡើយ ដោយហេតុថាដើមចោទទាមទារឱ្យដាក់ប្លង់ដីផ្ទះដែលគាត់ស្នាក់នៅ ដើម្បីយកប្រាក់ពីគេបន្តមកឱ្យកូនក្ដីខ្លួន ប៉ុន្តែពេលនោះកូនក្ដីខ្លួនក៏បានប្រាប់ថាប្លង់ជាប់នៅធនាគារហើយ។ ដោយភាគីដើមចោទបានដឹងយ៉ាងច្បាស់ថា កិច្ចសន្យាខ្ចីប្រាក់ដែលមានពិតប្រាកដ និងដែលបានបង្កើតកន្លងមកនោះបានហួសអាជ្ញាយុកាល ភាគីចុងបណ្ដឹងតបក៏បានយកឯកសារដែលកូនក្ដីខ្ញុំបាទបានផ្ដិតមេដៃលើកចុងក្រោយ យកមកកែប្រែបំពេញបន្ថែមចំណុចដែលមិនបានសរសេរអំពីចំនួនទឹកប្រាក់, សរសេរកាលបរិច្ឆេទនៃការខ្ចីប្រាក់មិនឱ្យហួសអាជ្ញាយុកាល ក្នុងគោលបំណងទុចរិតដើម្បីប្ដឹងទាមទារប្រាក់ពីកូនក្ដីខ្ញុំខ្លួន។

-បណ្ដឹងដើមរបស់ភាគីដើមចោទធ្វើឡើងមកកាន់កូនក្ដីខ្លួនគឺពុំមានភាពត្រឹមត្រូវឡើយ ដោយហេតុថា គឺធ្វើឡើងដោយបំពានអង្គហេតុពិតប្រាកដទាំងស្រុង។ កូនក្ដីខ្ញុំបាទពុំបានធ្វើការខ្ចីប្រាក់ម្ដងសរុប $១០១,៥៥០ ដុល្លារអាមេរិកនោះទេ ពោលគឺបានធ្វើការខ្ចីជាដំណាក់កាលៗ ដោយខ្ចីចាប់តាំងពីឆ្នាំ ២០១៥ មករហូតដល់ឆ្នាំ ២០១៦ ដូចដែលមានបញ្ជាក់នៅក្នុងកិច្ចសន្យាចំនួន ២៩ច្បាប់ ដូចដែលមានលម្អិតនៅក្នុងតារាងបញ្ជីកិច្ចសន្យាដែលផុតអាជ្ញាយុកាល ។

- កិច្ចសន្យាខ្ចីប្រាក់ចំនួន ២៩ ច្បាប់ ដែលកូនក្ដីខ្ញុំបាទបានចុះជាមួយភាគីដើមចោទ គឺផុតសុពលភាពនៃការទាមទារហើយ ពោលគឺបានផុតអាជ្ញាយុកាល នៃការទាមទារចំនួន ៥ឆ្នាំ ដោយដើមចោទមិនមានសិទ្ធិក្នុងការទាមទារបំណុលពីកូនក្ដីខ្ញុំបាទទៀតនោះទេ។

-កិច្ចសន្យាខ្ចីប្រាក់ដែលភាគីដើមចោទបានដាក់ជាភស្តុតាងប្ដឹងទាមទារប្រាក់ពីកូនក្ដីខ្ញុំបាទនោះគឺពុំមានភាពត្រឹមត្រូវនោះឡើយ។ នៅពេលដែលកូនក្ដីខ្ញុំបាទបានផ្ដិតមេដៃលើកិច្ចសន្យាលក់ទិញនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៧ គឺបានផ្ដិតលើកិច្ចសន្យានោះជាច្រើនច្បាប់ ដែលមានការចំហរនូវប្រាក់ដើម ការប្រាក់ និងទ្រព្យធានា ដែលអាចឱ្យម្ចាស់បំណុលធ្វើការបំពេញបន្ថែមនូវចំណុចទាំងអស់នេះតាមក្រោយបាន។

- នៅថ្ងៃផ្ដិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៧ នោះគឺផ្ដិតក្នុងគោលបំណងខ្ចីប្រាក់ចំនួន ២ ម៉ឺនដុល្លារអាមេរិក តែប៉ុណ្ណោះ ដោយមិនបានធ្វើការខ្ចីប្រាក់រហូតដល់ ១០១,៥៥០$ ដុល្លារអាមេរិកនោះទេ ហើយការខ្ចីចំនួន ២ ម៉ឺនដុល្លារអាមេរិកនោះ ក៏កូនក្ដីខ្ញុំពុំទទួលបាននូវសាច់ប្រាក់នោះដែរគឺគ្រាន់តែបានផ្ដិតមេដៃចោលតែប៉ុណ្ណោះ ដោយសំអាងថាមានការស្គាល់គ្នា និងរាប់អានគ្នាជិតស្និត ដែលជាធម្មតាការខ្ចីប្រាក់ម្ដងៗគឺទម្លាប់ផ្ដិតមេដៃចោលលើឯកសារខ្ចីប្រាក់។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
កណ្ដាល, ថ្ងៃទី 05 ខែ [illegible] ឆ្នាំ 2024
ក្រឡាបញ្ជី

[redacted]

-នៅក្នុងឯកសារកិច្ចសន្យា ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៧ ដែលខ្ចីប្រាក់ចំនួន ១០១,៥៥០$ ដុល្លារអាមេរិក នោះជាឯកសារមិនត្រឹមត្រូវ ដែលមានភាពខុសគ្នា ពីទម្រង់ឯកសារខ្ចីប្រាក់ចំនួន ២៩ច្បាប់ ដែលគូភាគីធ្លាប់ចុះពីមុនៗមក ។ ឯកសារកិច្ចសន្យានេះធ្វើឡើងដោយមានភាពមិនប្រក្រតី និងមានវិការៈជាច្រើន ដោយមានការបំពេញបន្ថែមនូវទឹកប្រាក់ ដែលជាធម្មតាការខ្ចីប្រាក់រវាងកូនក្តីខ្លួន និងដើមចោទមានការប្រាក់ក្នុងមួយខែ ៣% តែបែរជាកិច្ចសន្យាចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ មានការប្រាក់ ១,៥% ក្នុងមួយខែទៅវិញ។

-កិច្ចសន្យានេះគឺធ្វើឡើងដោយមិនមានភាពត្រឹមត្រូវ ដោយកូនក្តីខ្លួនមិនអាចធ្វើការពិនិត្យមើលខ្លឹមសារនៃកិច្ចសន្យាទាំងមូលបាននោះទេ ពោលគឺនៅពេលដែលផ្តិតមេដៃលើកិច្ចសន្យានោះគឺ ភាគីដើមចោទបានធ្វើការបាំងនូវខ្លឹមសារនៃកិច្ចសន្យាទាំងមូល ដោយបើកឱ្យផ្តិតយ៉ាងលឿន ។ ចំពោះឯកសារទាំងអស់នោះគឺធ្វើការផ្តិតដោយពុំបានពិនិត្យមើលថាតើមានអ្វីខ្លះនោះទេ គឺគ្រាន់តែផ្តិតចោលដោយចំហជាច្រើនចំណុចមិនត្រឹមតែប៉ុណ្ណោះគឺថាមានការផ្តិតចោលជាច្រើនសន្លឹក។

-ការធ្វើការចុះកិច្ចសន្យានោះធ្វើឡើង ដោយមានវិការៈ ដោយហេតុថាកូនក្តីខ្លួន ពុំបានពិនិត្យមើលខ្លឹមសារឱ្យបានអស់នោះទេ ហើយមានការគៀបសង្កត់ពីសំណាក់ភាគីម្ចាស់បំណុលដោយឱ្យផ្តិតចោលលើឯកសារទទេ។ គ្រាន់តែកូនក្តីខ្លួនសួរនាំបន្តិចបន្តួចក៏មិនបាន ដើមចោទបានប្រើពាក្យសំដីសំឡុត,ជេរប្រមាថ និងមើលងាយសម្លុតគំរាមថាឱ្យផ្តិតលើឯកសារទាំងនោះ ស្របពេលដែលកូនក្តីខ្លួនមិនសូវបានរៀនសូត្រខ្ពង់ខ្ពស់ និងមានការភ័យខ្លាចពីការជំពាក់ប្រាក់ផងនោះ ទើបកូនក្តីខ្លួនផ្តិតមេដៃទៅតាមការគំរាមសម្លុតតែម្តងទៅ។

-ដោយហេតុថាកិច្ចសន្យាដែលបានចុះនោះភាគច្រើនហួសអាជ្ញាយុកាលនៃការទាមទារ ទើបដើមចោទមានចេតនាទុច្ចរិត ក្នុងការរៀបចំកិច្ចសន្យាដែលបានផ្តិតមេដៃទទេរចំហាចោលក្នុងឆ្នាំ ២០១៧ មកបំពេញបន្ថែមដាក់ទឹកប្រាក់សរុបចំនួន $១០១,៥៥០ ដុល្លារអាមេរិក ព្រមទាំងសរសេរបន្ថែមនៅចំណុចការប្រាក់ ៣% ទៅវិញ។ នេះជាចេតនាទុច្ចរិតរបស់ម្ចាស់បំណុលក្នុងការធ្វើឯកសារថ្មីដើម្បីយកជាឯកសារ ភស្តុតាងទាមទារថ្មី ផ្ទុយពីការពិត។

**៤-<u>ចំណុចវិវាទៈ</u>**

១.ការទាមទារប្រាក់ដើម និងការប្រាក់របស់សហដើមចោទមានលក្ខណៈត្រឹមត្រូវដែរឬទេ?

២.តើកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១១.០៥.២០១៧ និងកិច្ចសន្យាស្តីពីការប្រាក់ចុះថ្ងៃទី១៦.១១.២០១៧ ដែលបានបង្កើតឡើងរវាងសហដើមចោទ និងសហចុងចម្លើយនោះ ថាតើជាកិច្ចសន្យាដែលមានវិការៈ អាចប្តឹងសុំមោឃភាពបានដែរឬទេ។

**៥. ចំណុចគ្មានវិវាទៈ** គ្មាន ។

**សំអាងហេតុ**

១.តាមការពិនិត្យលើពាក្យបណ្តឹងចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២២ របស់ដើមចោទ ឃើញថា មានលក្ខណៈត្រឹមត្រូវតាមច្បាប់ តាមមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ថ្ងៃទី 05 ខែ ... ឆ្នាំ 2024
ក្រឡាបញ្ជី



[redacted]

Scanned with CamScanner

២.តាមការអះអាងរបស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយសហដើមចោទថា សហដើមចទឈ្មោះ [redacted] សុធា និងឈ្មោះ [redacted] ស៊ីវអេង បានព្រមព្រៀងឲ្យសហចុងចម្លើយឈ្មោះ [redacted] ស្រេន និងឈ្មោះ [redacted] សាត ខ្ចីប្រាក់ចំនួន USD ១០១.៥៥០ (ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) សម្រាប់រយៈពេល ០៦ ខែ ក្នុងអត្រាការប្រាក់ ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង ០១ខែ ដោយមានកិច្ចសន្យាស្តីពីការខ្ចីប្រាក់ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៧ ដោយបានទ្រព្យធានាជាដីលំនៅដ្ឋាន និងផ្ទះ ទំហំ ២៥ម៉ែត្រ x បណ្តោយ ៥០ ម៉ែត្រ ដែលមានព្រំប្រទល់ ខាងជើងទល់ដីឈ្មោះ [redacted] ផេន និងឈ្មោះ [redacted],ខាងត្បូងទល់ថ្នល់ ,ខាងកើតទល់ ឈ្មោះ [redacted] និងឈ្មោះ [redacted] និងខាងលិចទល់ដីឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] ជ្រឹប និងដីស្រែនៅចំណុចស្វរដះពីក្បាលទំហំ ២០ម៉ែត្រ X ២០ ម៉ែត្រ និង ៤០ម៉ែត្រ X ១២០ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ដីឈមោះ ឈុំ គាំ, ខាងត្បូងទល់ផ្លូវ , ខាងកើតទល់ដីឈ្មោះ រឿន ខ្វាន, ខាងលិចទល់ដីឈ្មោះ [redacted] ឡេង នៅភូមិជន្លឹង ឃុំកោះជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងនៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៧ ឈ្មោះ [redacted] ស្រេន និងឈ្មោះ [redacted] បូរ៉ា បានខ្ចីប្រាក់ពីឈ្មោះ [redacted] សុធា និងឈ្មោះ [redacted] ស៊ីវអេង ចំនួន ៦០០០ $(មួយពាន់ដុល្លារអាមេរិក) បន្ថែមទៀត រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៨ សម្រាប់រយៈពេល ០៦ខែ ក្នុងអត្រាការប្រាក់ ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង ០១ខែ។ សហចុងចម្លើយបានព្រមព្រៀងដាក់បញ្ចាំរថយន្តម៉ាក HIGH LANDER ផលិតនៅឆ្នាំ២០០១ ពាក់ស្លាកលេខភ្នំពេញ 2AG 8043 ដែលមានឈ្មោះ [redacted] បូរ៉ា ជាម្ចាស់កម្មសិទ្ធិ។ ប៉ុន្តែចាប់ពីពេលខ្ចីនោះមកសហចុងចម្លើយពុំបានសងប្រាក់មកដើមចោទរហូតមកដល់បច្ចុប្បន្ន សហចុងចម្លើយពុំបាន បំពេញកាតព្វកិច្ចរបស់ខ្លួនរហូតមក ទោះបីជាដើមចោទបានទាក់ទងដាស់តឿន និងជូនដំណឹងឱ្យមកបំពេញកាតព្វកិច្ចតាមកិច្ចសន្យាក៏ដោយ ក៏សហចុងចម្លើយពុំបានចូលមកធ្វើការទូទាត់ប្រាក់ជំពាក់ជូនដើមចោទដែរ។ តុលាការទទួលស្គាល់ថា ពិតជាមាននូវអង្គហេតុដែលអះអាងដោយដើមចោទ ប្រាកដមែនដោយផ្អែកតាមមាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៣.ចំពោះការទាមទារឱ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ប្រាក់ដើមដែលនៅជំពាក់ចំនួន ១០១ ៥៥០$ (ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) និងប្រាក់ដើមចំនួន ៦០០០ $(ប្រាំមួយពាន់ដុល្លារអាមេរិក) ដោយផ្អែកលើភស្តុតាងតាមជាកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ជាមួយនឹងការប្រាក់ គប្បីតុលាការពិចារណា និងបង្គាប់ឱ្យសហចុងចម្លើយធ្វើការសងប្រាក់ដើមទាំងអស់ទៅឱ្យដើមចោទ ដោយផ្អែកតាមមាត្រា ៥៧៨, មាត្រា ៥៨៣ និងមាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី។

ច្បាប់ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
កណ្ដាល. ថ្ងៃទី 05 ខែ ... ឆ្នាំ 2024
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner

៤.ចំពោះការទាមទារការប្រាក់ចំនួន ១.៥%(មួយក្បៀសប្រាំភាគរយ) ក្នុង ០១ ខែ លើប្រាក់ដើមដែលនៅជំពាក់ចំនួន ១០១.៥៥០ $(ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) គិតពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងគ្រប់ និងការប្រាក់ចំនួន ១.៥% (មួយក្បៀសប្រាំភាគរយ) ក្នុង០១ ខែ លើប្រាក់ដើមដែលនៅជំពាក់ចំនួន ៦០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក) គិតពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់សងគ្រប់ចំនួន។ តុលាការបានពិចារណាឃើញថា គូភាគីបានព្រមព្រៀងគ្នា ដោយមានស្នាមេដៃ និងសាក្សីដឹងឮទៀតផង ម្យ៉ាងទៀតការព្រមព្រៀងលើអត្រាការប្រាក់នេះគឺស្ថិតក្នុងការកំណត់ដែលមានចែងក្នុងប្រកាសលេខ: ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ដែលបានកំណត់អត្រាការប្រាក់មិនឲ្យលើសពី ១៨% ក្នុងមួយឆ្នាំ គប្បីតុលាការសម្រេចអំពីការប្រាក់តាមការព្រមព្រៀងរបស់គូភាគី ។

៥.ការទាមទារឲ្យសហចុងចម្លើយ និងជាដើមបណ្ដឹងតបឈ្មោះ [redacted] ស្រេន,ឈ្មោះ [redacted] សាត និងឈ្មោះ [redacted] បូរ៉ា សងជំងឺចិត្ត ការខាតបង់ពេលវេលា និងការចំណាយសេវាកម្មច្បាប់សរុបចំនួន ៣០.០០០$(បីម៉ឺនដុល្លារអាមេរិក) នោះគប្បីតុលាការពិចារណាទៅលើការខូចខាតជាក់ស្តែង។

៦.តាមការអះអាងរបស់អ្នកតំណាងឲ្យចុងចម្លើយ និងជាដើមបណ្ដឹងតបថា កូនក្ដីរបស់ខ្លួនបានខ្ចីប្រាក់ពីសហចុងបណ្ដឹងតបតាំងពីឆ្នាំ២០១៥ បន្តរហូតមកដោយខ្ចីជាដំណាក់កាលៗ ជាហូរហែរ ដូចមានកិច្ចសន្យាទាំង២៩ច្បាប់គឺ:

1. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦
2. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦
3. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦
4. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦
5. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦
6. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦
7. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦
8. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៦
9. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦
10. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៦
11. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦
12. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥
13. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥
14. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥



បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
កណ្ដាល, ថ្ងៃទី 05 ខែ ... ឆ្នាំ 2024
ក្រឡាបញ្ជី
[redacted]

Scanned with CamScanner

15. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥
16. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥
17. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៥
18. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៥
19. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៥
20. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥
21. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥
22. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥
23. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥
24. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥
25. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៥
26. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ខែវិច្ឆិកា ឆ្នាំ២០១៥
27. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥
28. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ និង
29. កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥។

ចាប់តាំងពីបានខ្ចីនោះមកសហចុងបណ្តឹងតបពុំបានទាមទារឲ្យសហដើមបណ្តឹងតបសងប្រាក់មកខ្លួនទេ រហូតដល់កិច្ចសន្យាជាច្រើនហួសអាជ្ញាយុកាល នៃការទាមទារដែលច្បាប់បានកំណត់ មានរយៈពេល ៥ឆ្នាំ តែការលើកឡើងនេះតុលាការពុំលើកមកពិចារណាទេ ព្រោះថា ផ្ទុយនឹងកម្មវត្ថុនៃពាក្យបណ្តឹងដើមទាំងស្រុង។

៧.តាមកិច្ចសន្យាស្តីពីការខ្ចីប្រាក់ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០១៧ គឺបានកំណត់រយៈពេល ០៦ខែ គឺត្រឹមថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៧ ហើយចាប់តាំងពីពេលនោះមកគឺមានរយៈពេល ០៤ ឆ្នាំ ៨ខែ ២២ថ្ងៃ គឺស្ថិតក្នុងអាជ្ញាយុកាលនៃការអនុវត្តនៅឡើយ និងកិច្ចសន្យាស្តីការខ្ចីប្រាក់ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១៨ របស់គូរភាគី គឺនៅមានតម្លៃនៃការអនុវត្តនៅឡើយ ដូច្នេះគប្បីតុលាការលើកមកពិចារណា។

៨.ចំពោះការសុំអនុវត្តបណ្តោះអាសន្ន តុលាការពិចារណាបានចំពោះប្រាក់ដើម ដោយសារជាការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ និងមានការចាំបាច់ផ្អែកតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៩.យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

**សេចក្តីសន្និដ្ឋាន:**

-តុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទចំពោះប្រាក់ដើម។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ថ្ងៃទី 05 ខែ ... ឆ្នាំ 2024

[redacted]



Scanned with CamScanner

-តុលាការទទួលស្គាល់ការទាមទារការប្រាក់ផ្អែកតាមប្រកាសរបស់ក្រសួងយុត្តិធម៌ ។

-ការអនុវត្តបណ្ដោះអាសន្ន អាចធ្វើទៅលើប្រាក់ដើម។

-សហចុងចម្លើយត្រូវទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី ។

**សេចក្ដីសម្រេចបញ្ចប់**

**១**.ទទួលស្គាល់បណ្ដឹងទាមទាររបស់ដើមចោទឈ្មោះ [redacted] សុធា ភេទប្រុស កើតនៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៥៣ និងប្រពន្ធឈ្មោះ [redacted] ស៊ីវអេង កើតនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៧៥ ទុកជាត្រឹមត្រូវតាមច្បាប់។

២.បង្គាប់ឱ្យសហចុងចម្លើយ៖

២/១.ឈ្មោះ [redacted] ស្រេន ភេទប្រុស កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៦៩ និងប្រពន្ធឈ្មោះ [redacted] សាត កើតនៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ១៩៧១ មានអាសយដ្ឋានសព្វថ្ងៃនៅ [redacted]។

សងប្រាក់ទៅឲ្យសហដើមចោទឈ្មោះ [redacted] សុធា ភេទ ប្រុស កើតនៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៥៣ និងប្រពន្ធឈ្មោះ [redacted] ស៊ីវអេង ភេទស្រី កើតនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៧៥ មានអាសយដ្ឋាននៅភូមិក្នុង [redacted]។

នូវ ៖

២/១.១-ប្រាក់ដើមចំនួន ១០១ ៥៥០$ (ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) ។

២/១.២-ការប្រាក់ចំនួន ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង ០១ខែ លើប្រាក់ដើមចំនួន ១០១ ៥៥០$ (ដប់ម៉ឺនមួយពាន់ប្រាំរយហាសិបដុល្លារអាមេរិក) គិតពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងគ្រប់។

២/២.ឈ្មោះ [redacted] ស្រេន ភេទប្រុស កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៦៩ និងប្រពន្ធឈ្មោះ [redacted] សាត កើតនៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ១៩៧១ មានអាសយដ្ឋានសព្វថ្ងៃនៅ [redacted] និងឈ្មោះ [redacted] បូរ៉ា ភេទប្រុស កើតថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦ មានអាសយដ្ឋានសព្វថ្ងៃនៅ [redacted]។

សងប្រាក់ទៅឲ្យសហដើមចោទឈ្មោះ [redacted] សុធា ភេទ ប្រុស កើតនៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៥៣ និងប្រពន្ធឈ្មោះ [redacted] ស៊ីវអេង ភេទស្រី កើតនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៧៥ មានអាសយដ្ឋាននៅភូមិក្នុង [redacted]

នូវ៖

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ថ្ងៃទី 05 ខែ ... ឆ្នាំ 2024
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner

២/២.១-ប្រាក់ដើមចំនួន ៦០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក)។

២/២.២-ការប្រាក់ចំនួន ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង០១ខែ លើប្រាក់ដើមចំនួន ៦០០០ $(ប្រាំមួយពាន់ដុល្លារអាមេរិក) គិតពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់សងគ្រប់ចំនួន ។

៣.បង្គាប់ឲ្យសហចុងចម្លើយសងប្រាក់សំណងជម្ងឺចិត្ត សេវាកម្មច្បាប់ សរុបចំនួន ២០.០០០.០០០៛ (ម្ភៃលានរៀល)។

៤.ចំណុច ២/១.១ និងចំណុច ២/២.១ នៃសេចក្តីសម្រេចបញ្ចប់នេះ អាចអនុវត្តជាបណ្តោះអាសន្នបាន ។

៥.ច្រានចោលការទាមទារក្នុងបណ្តឹងតបរបស់សហចុងចម្លើយឈ្មោះ [redacted] ស្រេន ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] សាត និងឈ្មោះ [redacted] ប៊ូរ៉ា ភេទប្រុស ។

៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី ២១ ខែមីនា ឆ្នាំ២០២៣។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃអង្គារ១៥រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦

ខេត្តកណ្តាល ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃអង្គារ១៥រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦

ខេត្តកណ្តាល,ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

កណ្តាល, ថ្ងៃទី 05 ខែ ... ឆ្នាំ 2024

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner